# របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកចុងកាល់ ស្រុកត្រពាំងប្រាសាទ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប អមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣១ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរ មានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ក្រុងស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- ថ្ងៃទី ២១ ខែមិថុនា លោកអនុប្រធានមន្ទីរ ចូលរួមប្រជុំប្រចាំឆមាសទី ១ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តី និងកុមារខេត្តឧត្តរមានជ័យ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៤ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីពិនិត្យ ពិភាក្សា និងឆ្លងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៦-២០១៨) របស់រដ្ឋបាលខេត្ត ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលប្រជុំធំសាលាខេត្ត
- ថ្ងៃទី ២៤ ខែមិថុនា លោកអនុប្រធានមន្ទីរ ចូលរួមប្រជុំគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋថ្នាក់ខេត្ត ក្រុង ស្រុក ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលប្រជុំធំសាលាខេត្ត
- ថ្ងៃទី ០១ ខែកក្កដា លោកអនុប្រធានមន្ទីរ ចូលរួមប្រជុំបច្ចេកទេសចម្រុះវិស័យអប់រំ ថ្នាក់ក្រោមជាតិ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ថ្ងៃទី ០៧ ខែកក្កដា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី២៦ របស់ក្រុមប្រឹក្សាខេត្ត ឆ្នាំទី ២ អាណត្តិទី ២ នៅសាលប្រជុំធំសាលាខេត្ត
- ថ្ងៃទី ០៧ ខែកក្កដា មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ បានរៀបចំការប្រជុំការប្រជុំផ្សព្វផ្សាយស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា នៅសាលប្រជុំធំរបស់មន្ទីរ
- ថ្ងៃទី០៨ ខែកក្កដា លោកអនុប្រធានមន្ទីរ ០១រូប និងប្រធានការិយាល័យគណនេយ្យ ចូលរួមប្រជុំពិភាក្សាអំពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការរៀបចំរបាយការណ៍លទ្ធកម្មសាធារណៈរបស់

អង្គភាពថវិកា នៅសាលប្រជុំធំសាលាខេត្ត

- ថ្ងៃទី ១២ ខែកក្កដា លោកអនុប្រធានមន្ទីរ ចូលរួមប្រជុំ Pro TWG-H ប្រចាំខែមិថុនា នៅមន្ទីរសុខាភិបាលខេត្ត និង
- ថ្ងៃទី ១៨ ខែកក្កដា មន្ត្រីជំនាញ ០២ រូប ចូលរួមប្រជុំពិភាក្សា ស្តីពីសេចក្តីព្រាងការរៀបចំផែនការថវិកាឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **ហួត សារឹម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវបានសាងសង់រួច នៅភូមិបាត់ថ្កោ ឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែង ៤.៥០០ ម៉ែត្រ សម្រេចបានលទ្ធផល ១០០%
- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវកំពុងជួសជុល ចាប់ពីភូមិបន្ទាយថ្មី ឃុំចុងកាល់ ដល់ផ្លូវក្រុមហ៊ុន ប្រវែង ៩.៩៥០ ម៉ែត្រ ជួសជុលសម្រេចបានលទ្ធផល ៥០ %
- អមដំណើរក្រុមការងារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះត្រួតពិនិត្យបញ្ចប់សុពលភាពផ្លូវជួសជុលឆ្នាំ ២០១៥ ប្រវែង ១១.៥០០ ម៉ែត្រ ភូមិតាម៉ា ភូមិវល្លិយាវ ឃុំបេង ស្រុកបន្ទាយអំពិល ដឹកនាំដោយលោក **ហេង សុខអេង** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ
- សាងសង់លូភ្លោះមុខ ៦០ បន្ទាន់ ០១ កន្លែង នៅភូមិបាត់ថ្កោ ឃុំចុងកាល់ ស្រុកចុងកាល់ លើខ្សែផ្លូវប្រវែង ៤.៥០០ ម៉ែត្រ សម្រេចបានលទ្ធផល ១០០%
- ចុះត្រូវពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវថែទាំខួប ឆ្នាំ ២០១៦ សាងសង់នៅភូមិក្រូចសាខន ភូមិស្រះព្រិច សង្កាត់កូនក្រៀល ប្រវែង ៧.៥០០ មែត្រ សម្រេចបានលទ្ធផល ៨0%
- ថ្ងៃទី ១៨ ខែកក្កដា លោកប្រធានមន្ទី លោកអនុប្រធានមន្ទីរ និងប្រធានការិយាល័យ ចូលរួមប្រជុំពិភាក្សាជ្រើសរើសខ្សែផ្លូវអាទិភាពសម្រាប់ផែនការថែទាំផ្លូវ ប្រចាំឆ្នាំ ២០១៧ ក្រោមអធិបតីភាពឯកឧត្តម **សួស គង់** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍ៍ជនបទ។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- ថ្ងៃទី ២១-២៤ ខែមិថុនា មន្ត្រីការិយាល័យ ០១ រូប ចូលរួមទស្សនកិច្ចសិក្សាជាមួយអង្គការប្រា (CHHRA)ស្វែងយល់អំពីបៀបសាងសង់បង្គន់អនាម័យ និងការប្រើប្រាស់ទឹកសុវត្ថិភាពតាមគ្រួសារ (Household water treatment standard )នៅភូមិពោធិ៍ថ្មី ឃុំបេង និងភូមិសឹង្ហ ឃុំគោកមន ស្រុកបន្ទាយអំពិល មានប្រជាពលរដ្ឋចូលរួម សរុបចំនួន ១៨៧ គ្រួសារ
- ថ្ងៃទី ២៩ ខែមិថុនា មន្ត្រីបច្ចេកទេសការិយាល័យផ្គត់ផ្គង់ទឹកជនបទបានចុះត្រួតពិនិត្យការងារសាងសង់អណ្តូងស្នប់ចំនួន ០២ អណ្តូងរួមមាន÷
    - សាងសង់អណ្តូងស្នប់ ០១ អណ្តូង មានទីតាំងស្ថិតនៅភូមិព្រៃធំ ឃុំចុងកាល់ ស្រុកចុងកាល់

អ្នកទទួលការបានខ្ទង់ និងតម្លើងបំពង់រួច មានជម្រៅ ៣០ ម៉ែត្រ ធារទឹក ២.០០ ម៉ែត្រគូប នីវ៉ូស្តាទិច ៨ ម៉ែត្រ និងនីវ៉ូឌីណាមិច ១៨ ម៉ែត្រ និង

- សាងសង់អណ្តូងស្នប់ ០១ អណ្តូងមានទីតាំងស្ថិតនៅភូមិ "ក" ឃុំចុងកាល់ ស្រុកចុងកាល់ អ្នកទទួលការបានខ្ទង់ និងតម្លើងបំពង់រួច មានជម្រៅ ៣៤ ម៉ែត្រ ធារទឹក ១.៧ ម៉ែត្រគូប នីវ៉ូស្តាទិច ៥ ម៉ែត្រ និងនីវ៉ូឌីណាមិច ២៦ ម៉ែត្រ។

### ៣.៣ ការងារថែទាំសុខភាពជនបទ

- ថ្ងៃទី ០៤-០៥ ខែកក្កដា ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអភិក្រមប្រកបដោយ សុខុដុមនីកម្មក្នុងការផ្ទេរថវិកាដល់ដៃគូរអនុវត្តគម្រោងក្រោមអធិបតីភាព ឯកឧត្តម **ទ្រី ម៉េង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ រៀបចំឡើងដោយក្រុមការងាររដ្ឋបាល និងហិរញ្ញវត្ថុនៃគម្រោង យូនីសេហ្វ ក្រោមការគាំទ្រថវិកាដោយអង្គការ Unicef នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។ សិក្ខាកាមចូលរួមមកពី នាយកដ្ឋានថែទាំសុខភាពជនបទ នាយក ដ្ឋានផ្គត់ផ្គង់ជនបទ តំណាងអង្គការ Unicef និងមន្ត្រីមកពីមន្ទីរអភិវឌ្ឍន៍ជនបទទាំង ១៥ ខេត្តគោលដៅ សរុបចំនួន ៤២ នាក់ ស្ត្រីចំនួន ០៨ នាក់
- ថ្ងៃទី ០៨ ខែកក្កដា មន្ត្រីការិយាល័យចំនួន ០៣ រូប អមដំណើរមន្ត្រីតំណាងអង្គការ Unicef ០១ រូប ចុះធ្វើការពិនិត្យ និងសិក្សាពីដំណើរការប្រតិបត្តិ អនាម័យរបស់ប្រជាពលរដ្ឋនៅក្នុងភូមិដែលបានក្លាយជាភូមិបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលទាំងស្រុង។ លទ្ធផលសម្រេច និងការកែលម្អ÷
    1. ភូមិអូរក្រវ៉ាន់ ខ្នងផ្ទះមានបង្គន់ប្រើប្រាស់គ្រប់គ្រាន់ និងអត្រាប្រតិបត្តិអនាម័យមានលក្ខណៈល្អប្រសើរ
    2. ភូមិឈូក ចំនួនខ្នងផ្ទះមិនទាន់មានបង្គន់ប្រើប្រាស់គ្រប់គ្រាន់ ហើយគ្រួសារដែលគ្មានបង្គន់នៅបន្តបន្ទោរបង់ពាសវាលពាសកាលដដែល ដូច្នេះមន្ទីរ និងភូមិត្រូវធ្វើការជំរុញបន្ថែមទៀតឱ្យគ្រួសារដែលមិនទាន់មានបង្គន់ត្រូវសាងសង់ដើម្បីប្រើប្រាស់ជាប្រចាំ។
- ថ្ងៃទី ០៨-១១ ខែកក្កដា មន្ត្រីការិយាល័យចំនួន ០២ រូប បានចុះរៀបចំការចាក់បញ្ចាំងវីដេអូអប់រំស្តីពីកម្មវិធីលើកកម្ពស់ទឹកស្អាត និងអនាម័យជនបទ គាំទ្រថវិកាដោយអង្គការ Unicef ដោយអនុវត្តបានចំនួន ០៤ ភូមិ គឺឃុំក្រសាំង ០២ ភូមិ និងឃុំចុងកាល់ ០២ ភូមិ ស្ថិតក្នុងស្រុកចុងកាល់ មានការចូលរួមពីមន្ត្រីមន្ទីរ ក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាពលរដ្ឋភូមិគោលដៅ សរុបចំនួន ២៧៦ នាក់ ស្ត្រី ១៣៥ នាក់ ។ គោលបំណងគឺបង្ហាញពីរបៀបសាងសង់ និងប្រើប្រាស់បង្គន់ ការផឹកទឹកមានសុវត្ថិភាព រួមទាំងបង្ហាញវីដេអូ ខ្លីៗ ស្តីពីប្រភពទឹក និងការប្រើប្រាស់ហើយនិងកត្តាប្រឈមនៅពេលគ្មានបង្គន់ប្រើប្រាស់ជាដើម
- ថ្ងៃទី ១៣-១៤ និង ១៨ ខែ កក្កដា មន្ត្រីការិយាល័យចំនួន ០៣ រូប បានចុះរៀបចំសម្របសម្រួលបើកកិច្ចប្រជុំត្រីមាសទី ២ ថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យក្នុងឃុំគោលដៅទាំង

០៥ គឺឃុំពង្រ ឃុំក្រសាំង ឃុំចុងកាល់ ស្រុកចុងកាល់ និងនៅសង្កាត់សំរោង សង្កាត់បន្សាយរាក់ ក្រុងសំរោង មានសិក្ខាកាមចូលរួមមកពីថ្នាក់មន្ទីរ ក្រុមប្រឹក្សាឃុំ មេភូមិ សមាជិកភូមិ និងនាយកសាលាសរុបចំនួន ១៣៦ នាក់ ស្ត្រី ២២ នាក់ ក្រោមការគាំទ្រថវិកាដោយ អង្គការ Unicef លទ្ធផលសម្រេចបាន÷

- ការបង្ហាញពីលទ្ធផលរីកចម្រើននៃការអនុវត្តគម្រោងរបស់មន្ទីរ
- ការសិក្សាពីកត្តាប្រឈម និងដំណោះស្រាយរួមគ្នានៅក្នុងអង្គប្រជុំ និង
- រៀបចំផែនការអនុវត្តបន្តរបស់ឃុំ ភូមិ និងសាលា សម្រាប់ត្រីមាសបន្ទាប់។

### ៣.៤ ការងារអភិវឌ្ឍន៍សហគមន៍

- បានបើកវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ០៥ វគ្គ ស្ថិតក្នុងសង្កាត់សំរោង ក្រុងសំរោង ០២ វគ្គ អ្នកចូលរួមសរុប ៧០ នាក់ ស្រី ១២ នាក់ នៅឃុំបេង ស្រុកបន្ទាយអំពិល ០២ វគ្គ អ្នកចូលរួមសរុប ៧០ នាក់ ស្រី ២៣ នាក់ និងឃុំគោកមន ស្រុកបន្ទាយអំពិល ០១ វគ្គ អ្នកចូលរួមសរុប ៣៥ នាក់ ស្រី ១២ នាក់។ វគ្គបណ្ដុះបណ្ដាលនេះឧបត្ថមថវិកាដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ នៃក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ០៤-០៧ ខែកក្កដា មន្ត្រីការិយាល័យ ០៣ រូប សហការជាមួយអង្គការ FH Cambodia បានចុះសម្របសម្រួលក្នុងវគ្គបណ្ដុះបណ្ដាល ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ចំនួន ០២ វគ្គ សរុប ១៥ ភូមិ ស្ថិតក្នុងស្រុកត្រពាំងប្រាសាទ មានអ្នកចូលរួមសរុប ១៦៥ នាក់ ស្រី ៦០ នាក់ និង
- ថ្ងៃទី ១៨-១៩ ខែកក្កដា លោកអនុប្រធានមន្ទីរ ០១ រូប និងប្រធានការិយាល័យ ចូលរួមសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ការងារពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តពោធិ៍សាត់។

### ៣.៥ ការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ថ្ងៃទី ២២-២៤ ខែមិថុនា ចុះស្រង់ទិន្នន័យជនជាតិដើមភាគតិច បានចំនួន ០៥ ឃុំ ក្នុងស្រុកអន្លង់វែង និង
- ថ្ងៃទី ១២-១៤ ខែកក្កដា ចុះស្រង់ទិន្នន័យជនជាតិដើមភាគតិច បានចំនួន ០៣ ឃុំ ក្នុងស្រុកត្រពាំងប្រាសាទ។

### ៣.៦ ការងារការិយាល័យអភិវឌ្ឍន៍ជនបទតាមបណ្ដាក្រុង/ស្រុក

#### ៣.៦.១ ការិយាល័យអភិវឌ្ឍន៍ជនបទក្រុងសំរោង

- ថ្ងៃទី ២៧-២៨ ខែមិថុនា ចូលរួមវេទិកាពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង នៅតាមបណ្ដាសង្កាត់ទាំង ០៥ ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ និង
- ថ្ងៃទី ២៩ ខែមិថុនា ចូលរួមប្រជុំសាមញ្ញលើកទី ២៥ អាណត្តិទី ២ របស់ក្រុមប្រឹក្សាក្រុងសំរោង។

### ៣.៦.២ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកបន្ទាយអំពិល

- ថ្ងៃទី ២៣ ខែមិថុនា ចូលរួមប្រជុំបណ្ដាញយេនឌ័រថ្នាក់ស្រុក
- ថ្ងៃទី ២៩ ខែមិថុនា ចូលរួមប្រជុំសាមញ្ញលើកទី ២៥ របស់ក្រុមប្រឹក្សាស្រុកបន្ទាយអំពិល និង
- ថ្ងៃទី ៣០ ខែមិថុនា ចូលរួមវគ្គបណ្ដុះបណ្ដាលរំលើកឡើងវិញ ស្ដីពីការកសាងផែនការកម្មវិធីវិនិយោគ បីឆ្នាំរំកិល របស់សាលាស្រុកបន្ទាយអំពិល។

## ៤. ទិសដៅការងារបន្ត

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវជួសជុល ដែលកំពុងអនុវត្ត
- ចុះត្រួតពិនិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់ ជួសជុលខួប សាងសង់ថ្មីទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៧
- ចុះប្រមូលទិន្នន័យខ្សែផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាព សម្រាប់ឆ្នាំ ២០១៦
- សាងសង់អណ្ដូងស្នប់អាហ្វ្រីដេវនៅភូមិសែនមនោរម្យ ១ ចំនួន ០២ អណ្ដូង និងភូមិសែនមនោរម្យ ២ ចំនួន ០២ អណ្ដូង ឃុំគោកមន
- សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ ធុង
- ចុះអប់រំផ្សព្វផ្សាយ និងត្រួតពិនិត្យ ស្ដីពីការប្រតិបត្តអនាម័យនៅតាមសហគមន៍ ចំនួន ៤៣ ភូមិ
- សម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ឃុំ ស្ដីពីកម្មវិធីទឹកស្អាត និងអនាម័យ
- សម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ស្រុក ស្ដីពីកម្មវិធីទឹកស្អាត និងអនាម័យ
- ចុះរៀបចំបញ្ចាំងវីដេអូ អប់រំអនាម័យ ពេលយប់នៅតាមសហគមន៍ ចំនួន ០៤ ភូមិ និង
- រៀបចំប្រមូលទិន្នន័យជនជាតិដើមភាគតិចចំនួន ០៤ ស្រុក ០១ ក្រុង ក្នុងខេត្តឧត្តរមានជ័យ។